សួស្តី នៅក្នុងរូបភាពនេះគឺនិយាយអំពីរោងកុន ដែលនៅក្នុងរូបភាពទី ១ យើងឃើញមានស្ត្រីម្នាក់
ដែលគាត់ពាក់អាវពណ៌ខៀវដៃខ្លី ជាមួយនឹងខោសជើងវែង សក់របស់គាត់ចងបួងឡើងទៅលើ
គាត់អង្គុយនៅលើកៅអីក្នុងផ្ទះរបស់គាត់។ នៅខាងមុខគាត់យើងឃើញមានតុមួយ
នៅខាងលើតុយើងឃើញមានកុំព្យូទ័រ
អញ្ចឹងគាត់កំពុងតែប្រើកុំព្យូទ័ររបស់គាត់ឆាតលេងជាមួយនឹងពួកម៉ាករបស់គាត់។
ជាទូទៅនៅកម្ពុជាភាគច្រើនយើងជជែកលេងជាមួយមិត្តភក្តិដោយការ
ដោយការលេងឆាតហ្វេសប៊ុក ដោយការលេងឆាតតាមហ្វេសប៊ុក ឬក៏តាមឡាញ ឬក៏តាមឡាញ
អញ្ចឹងហ្វេសប៊ុកនិងឡាញគឺពេញនិយមនៅកម្ពុជា។ អញ្ចឹងយើងបែរមកមើលស្ត្រីម្នាក់នេះវិញ គាត់
គាត់កំពុងតែលេងហ្វេសប៊ុក និងគាត់កំពុងតែលេងហ្វេសប៊ុក
ដោយសារតែថ្ងៃនេះគឺជាថ្ងៃឈប់សម្រាកផង ដូច្នេះគាត់ក៏បានបបួលពួកម៉ាករបស់គាត់តាមរយៈ
តាមរយៈការលេងឆាតតាមហ្វេសប៊ុក ដើម្បីទៅមើលកុនជាមួយគ្នា ដើម្បីទៅមើលកុនជាមួយគ្នា
ពីព្រោះការមើលកុន ប្រសិនបើយើងទៅតែម្នាក់ឯង ពេលខ្លះអត់សប្បាយ
និងពេលខ្លះមើលកុនដូចជាអត់ល្អមើល ប៉ុន្តែប្រសិនបានទៅជាមួយនឹងពួកម៉ាក ជាមួយនឹងសង្សារ
ឬក៏មិត្ត ជាមួយនឹងសង្សារ ឬក៏មិត្តប្រុស ឬក៏មិត្តស្រី ឬក៏ជាមួយគ្រួសារ មានអារម្មណ៍ថាសប្បាយ
និងកុននោះល្អមើល។ អញ្ចឹងគាត់ឆាតបបួលពួកម៉ាករបស់គាត់ ដើម្បីទៅមើលកុនជាមួយគ្នា
នៅថ្ងៃឈប់សម្រាកនេះ។

បន្ទាប់មកទៀតរូបភាពទី ២ រូបភាពទី ២ ក្រោយពីគាត់បបួល បបួល
ក្រោយពីគាត់បបួលពួកម៉ាករបស់គាត់ទៅមើលកុន ទៅមើលកុនជាមួយគ្នា
បន្ទាប់មកពួកម៉ាកគាត់បានយល់ព្រម
គាត់ក៏បានចេញទៅយកម៉ូតូរបស់គាត់ដែលដាក់នៅខាងក្រៅផ្ទះ និងជិះទៅ
និងជិះទៅផ្សារទំនើបដើម្បីទៅមើលកុន ដើម្បីទៅមើលកុន។
ជាទូទៅរោងកុននៅកម្ពុជាភាគច្រើននៅតាមផ្សារទំនើប នៅតាមផ្សារទំនើប
អញ្ចឹងមានតែរោងកុនមួយដែលនៅខាងក្រៅពីផ្សារទំនើប ក្រៅពីនេះភាគច្រើនគឺនៅក្នុងផ្សារទំនើប។
អញ្ចឹងគាត់បានណាត់ពួកម៉ាកគាត់នៅផ្សារ ផ្សារទំនើបជួបគ្នានៅខាងមុខផ្សារទំនើប
បន្ទាប់មកពួកគាត់ចូលទៅខាងក្នុងជាមួយគ្នា ប៉ុន្តែ ប៉ុន្តែដំបូងគាត់ជិះម៉ូតូទៅផ្សារទំនើបនោះសិន
យើងឃើញម៉ូតូរបស់គាត់មានកញ្ចក់ពីរសងខាង ដែលកញ្ចក់នោះប្រើសម្រាប់មើលផ្លូវក្រោយ
នៅពេលដែលគាត់ចង់បត់ឆ្វេង ឬក៏នៅពេលដែលគាត់ចង់បត់ស្តាំ
ឬក៏ឆ្លងថ្នល់ងាយស្រួលមើលទៅខាងក្រោយថាតើមានឡាន ឬក៏ម៉ូតូនៅខាងក្រោយទេ
ប្រសិនបើមាន អញ្ចឹងគាត់ត្រូវរង់ចាំ គាត់ត្រូវរង់ចាំរហូតដល់ម៉ូតូឡាននោះទៅផុតសិន
ដូច្នេះគាត់អាចឆ្លងបាន ប៉ុន្តែប្រសិនបើអត់មានទេគាត់អាចឆ្លងបាន អញ្ចឹងកញ្ចក់អាចជួយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អាចជួយគាត់មួយផ្នែកក្នុងការមើលផ្លូវខាងក្រោយ និងយើងឃើញគាត់ពាក់មួកសុវត្ថិភាព
ការពាក់មួកសុវត្ថិភាពគឺ គឺជាការការពារអាយុជីវិតរបស់យើង មានន័យថាមួកការពារសុវត្ថិភាព
គឺអាចជួយការពារក្បាលរបស់យើង នៅពេលដែលយើងដួល
ឬក៏នៅពេលដែលយើងមានគ្រោះថ្នាក់ដោយប្រការណាមួយដោយចៃដន្យ មួក
នៅពេលដែលយើងដួល ដួលបោកជាមួយនឹងថ្នល់ ឬក៏បោកជាមួយនឹងថ្ម
មួកការពារសុវត្ថិភាពអាចជួយការពារក្បាលរបស់យើងកុំឲ្យបែក ឬក៏កុំឲ្យមានរបួសបាន
ដូច្នេះជាទូទៅនៅពេលជិះម៉ូតូដាច់ខាតត្រូវពាក់មួកសុវត្ថិភាព និងម៉ូតូត្រូវមានកញ្ចក់
និងប្រសិនបើយើងជិះឡានត្រូវពាក់ខ្សែក្រវាត់ជានិច្ច ត្រូវពាក់ខ្សែក្រវាត់ឡានជានិច្ច។
អញ្ចឹងគាត់ជិះម៉ូតូយ៉ាងលឿនសំដៅទៅផ្សារទំនើប
ដើម្បីជួបពួកម៉ាករបស់គាត់ទៅមើលកុនជាមួយគ្នា។

បន្ទាប់មកទៀតរូបភាពទី ៣ រូបភាពទី ៣ ក្រោយពេលគាត់ជិះម៉ូតូយ៉ាងលឿន
គាត់ក៏បានមកដល់ផ្សារទំនើប។ បន្ទាប់មកគាត់ក៏បានយកម៉ូតូគាត់ទៅផ្ញើ ទៅផ្ញើនៅកន្លែងផ្ញើ
នៅកន្លែងផ្ញើម៉ូតូ បន្ទាប់មកគាត់ក៏បានដើរមកជួបពួកម៉ាករបស់គាត់នៅខាងមុខផ្សារទំនើប
អញ្ចឹងយើងឃើញពួកម៉ាករបស់គាត់រង់ចាំគាត់នៅខាងមុខផ្សារទំនើប
ពួកម៉ាករបស់គាត់គឺមកដល់មុនគាត់ យើងឃើញពួកម៉ាករបស់គាត់មានសក់ខ្លី មានសក់ខ្លី
គាត់ពាក់អាវយឺតពណ៌លឿង ដៃខ្លី និងសំពត់ពណ៌ខ្មៅ
អញ្ចឹងពួកគាត់មួយស្លៀកខោមួយស្លៀកសំពត់ ប៉ុន្តែពួកគាត់ពាក់អាវយឺតដូចគ្នា ប៉ុន្តែខុសត្រង់ពណ៌
ខុសត្រង់ពណ៌ និង និងពួកគាត់ ក្រោយពេលដែលបានជួបគ្នា
ក៏បានលើកដៃនិយាយសួស្តីទៅកាន់គ្នាទៅវិញទៅមក។
អញ្ចឹងយើងឃើញពួកម៉ាករបស់គាត់ឈរនៅខាងមុខផ្សារទំនើប ដោយគាត់មកដល់ផ្សារទំនើបមុន
អញ្ចឹងក្រោយពេលដែលស្ត្រីម្នាក់នោះគាត់បានចតម៉ូតូរួចរាល់ហើយ គាត់ក៏បានចូលមក
គាត់ក៏បានដើរចូលមកផ្សារ គាត់ក៏បានដើរមកខាងមុខផ្សារទំនើបដើម្បី
ដើម្បីជួបពួកម៉ាករបស់គាត់នៅទីនោះ។

បន្ទាប់មករូបភាពទី ៤ រូបភាពទី ៤ ពួកគាត់ទាំងពីរក៏ដើរចូលទៅក្នុងផ្សារទំនើប
និងឡើងទៅជាន់ខាងលើ ដើម្បីទិញសំបុត្រមើលកុន ដើម្បីទិញសំបុត្រមើលកុន
អញ្ចឹងពួកគាត់ទាំងពីរបានឡើងទៅដល់ខាងលើ បានឡើងទៅដល់រោងកុន
បន្ទាប់មកពួកគាត់ទាំងពីរក៏បានទិញសំបុត្រពីរដើម្បីចូលទៅមើលកុននៅខាងក្នុង។
នៅមុនពេលដែលយើងចូលទៅមើលកុន យើងត្រូវទិញសំបុត្រជាមុនសិន
និងមុនពេលទិញសំបុត្រយើងត្រូវជ្រើសរើសកន្លែងអង្គុយ ជាទូទៅមនុស្សគាត់ចូលចិត្ត ជាទូទៅ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ជាទូទៅមនុស្សចូលចិត្តអង្គុយនៅខាងក្រោយ ចូលចិត្តនៅអង្គុយនៅខាងក្រោយ កៅអីខាងក្រោយ ពីព្រោះអង្គុយនៅកៅអីខាងក្រោយងាយស្រួលមើល ប្រសិនបើយើងអង្គុយនៅកៅអីខាងមុខ ពេលខ្លះយើងអង្គុយជិត ជិត ជិត អង្គុយជិតពេកធ្វើឲ្យពេលខ្លះពិបាកមើល និងពេលខ្លះក៏ធ្វើឲ្យឈឺក្បាលផងដែរ ដោយសារតែយើងឃើញរូបភាពធំៗ ដោយសារតែយើងឃើញរូបភាពធំៗ និងពេលខ្លះយើងឃើញរូបភាពដូចជា ដូចជានៅខាងមុខយើង នៅខាងមុខយើងចំ អញ្ចឹងភាគច្រើនមនុស្សទាំងអស់គាត់ចូលចិត្តអង្គុយមើលខាងក្រោយ ដោយសារតែមើលខាងក្រោយ យើងអាចមើលឃើញតួសម្តែងដែលនៅក្នុងរោង ដែលនៅក្នុងកុននោះ យើងអាចមើលឃើញរាងតូចបន្តិច និងងាយស្រួលមើល និងងាយស្រួលមើល ដោយការសម្តែងនោះ មិន មិនមើលទៅដូចជាការសម្តែងនៅចំ នឹងភ្នែករបស់យើង ដូចជាការអង្គុយនៅខាងមុខទេ អញ្ចឹងជាទូទៅសំបុត្រនៅខាងក្រោយគឺ អ្នកខ្លះគឺគាត់កក់ទុកមុន មុនពេលដែលគាត់មកដល់ដោយការខលតាមទូរស័ព្ទ ពីព្រោះកៅអីខាងក្រោយ ពេលខ្លះប្រសិនបើកុននោះល្អមើលអត់មានកៅអីខាងក្រោយសម្រាប់អង្គុយទេ ដូច្នេះយើងត្រូវទិញកៅអីខាងមុខ អញ្ចឹងប្រសិនបើយើងចង់បានកៅអីអង្គុយខាងក្រោយ យើងត្រូវខលទៅ យើងត្រូវខលឬក៏តែទៅកាន់ យើងត្រូវខល ឬក៏តែទៅរោងកុន ដើម្បីឲ្យពួកគាត់ទុកកន្លែងអង្គុយនោះសម្រាប់យើង សំបុត្រកុនថ្លៃឬថោកអាស្រ័យទៅលើ អាស្រ័យទៅលើកុន កុនខ្លះគឺសំបុត្រកុនថ្លៃ កុនខ្លះគឺសំបុត្រកុនថោក។ អញ្ចឹងពេលខ្លះតម្លៃ ប៉ុន្តែសំបុត្រកុនខ្លះតម្លៃត្រឹមតែ ៣ ដុល្លារ ៤ ដុល្លារ ឬ៥ ដុល្លារ អញ្ចឹងកុនខ្លះដែលយើងការមើលហ្ស៊ីឌី ឬក៏ស្រ៊ីឌី អាចតម្លៃ ៩ ដុល្លារ ឬក៏ ១០ ដុល្លារ ឬក៏ ១១ ឬក៏ ១២ ដុល្លារ ទៅតាម ទៅតាមសាច់រឿង ឬក៏ទៅតាមកុនដែលពួកគាត់មើល។

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ ក្រោយពេលដែលពួកគាត់បានទិញសំបុត្រហើយ ពួកគាត់បានដើរមកកន្លែងដែលមានលក់ពោត ដែលមានលក់ពោត អញ្ចឹងពួកគាត់បានទិញពោតលីង ប៉ុន្តែពោតលីងនេះខុសពីពោតលីងដែលយើងលីងនៅផ្ទះ។ ពោតលីងនេះគឺយើងប្រើម៉ាស៊ីន និងពេលខ្លះយើងប្រើប៊ឺរដាក់ចូលជាមួយ ដើម្បីឲ្យមានក្លិនឈ្ងុយ។ ពោតលីងមួយទៀតយើងទិញ យើងទិញពោតមកប្រឡេះយកគ្រាប់របស់វា បន្ទាប់មកយើងលីងនៅផ្ទះគ្រាន់តែដាក់នៅក្នុងឆ្នាំង និងដាក់ទឹកអំបិលចូល អញ្ចឹងយើងហៅពោតលីងដូចគ្នា ប៉ុន្តែវិធីធ្វើខុសគ្នា និងក្លិន ពេលខ្លះក្លិនឈ្ងុយខុសគ្នា ដោយសារតែពោតលីងដែលយើងហៅថា popcorn នៅក្នុងរោងកុននោះគឺយើងមានដាក់ប៊ឺរ ដើម្បីឲ្យមានក្លិនឈ្ងុយ ប៉ុន្តែពោតលីង ពោតលីងដែលយើងលីងនៅផ្ទះរបស់យើង គឺយើងលីងដោយដៃរបស់យើងដោយមិនបានប្រើម៉ាស៊ីន និងយើងអត់ប្រើប៊ឺរទេ យើងប្រើទឹកអំបិល ដើម្បីឲ្យវាមានរសជាតិប្រៃបន្តិច អញ្ចឹងពួកគាត់បានទិញ popcorn

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏យើងហៅថាពោតលីងមួយប្រអប់ធំនៅក្នុងរោងកុន។ ជាទូទៅមុនពេលទៅមើល
មុនពេលមើលកុនពួកគាត់តែងតែទិញ popcorn ឬក៏យើងហៅថាពោតលីងនេះ ដើម្បី
ដើម្បីញ៉ាំលេងនៅក្នុងរោងកុន ដើម្បីញ៉ាំលេងនៅក្នុងរោងកុន ក្រៅពី ក្រៅពីពោតលីងនេះ
យើងអត់អាចទិញចំណីផ្សេងទៀតចូលទៅក្នុងរោងកុនបានទេ។
រោងកុនខ្លះដែលមិនស្ថិតនៅក្នុងផ្សារទំនើប ពួក ដែលមិនស្ថិតនៅក្នុងផ្សារទំនើប
យើងអាចទិញរបស់ខាងក្រៅចូលទៅខាងក្នុងបាន ដោយអ្នកខ្លះគាត់ទិញស្វាយ
គាត់ទិញរបស់ណាដែលរសជាតិជូរ គាត់ទិញ និងរបស់ញ៉ាំជាច្រើនចូលទៅខាងក្នុង នៅអំឡុង
នៅអំឡុងពេលដែលគាត់មើលកុនគាត់អាចញ៉ាំបាន
ប៉ុន្តែរោងកុនដែលស្ថិតនៅក្នុងផ្សារទំនើបភាគច្រើនពួកគាត់មិនអនុញ្ញាតឲ្យយើងយក
យកចំណីអាហារពីខាងក្រៅចូលទៅខាងក្នុងទេក្រៅពីពោត ក្រៅពីពោតលីង និងភេសជ្ជៈ
និងភេសជ្ជៈដែលបានទិញនៅកន្លែង ដែលបានទិញនៅកន្លែងដែលពួកគាត់លក់នោះ។
អញ្ចឹងគាត់មិនអនុញ្ញាតឲ្យ ឲ្យយើងយកចំណីពីខាងក្រៅចូលទៅខាងក្នុងទេ
ប្រសិនបើយើងមានចំណីពីខាងក្រៅយួរនៅក្នុងដៃ ពួកគាត់នឹងឲ្យ
ពួកគាត់នឹងយកចំណីនោះរក្សាទុកឲ្យយើងនៅក្នុងទូរហូតដល់យើងមើលកុនចប់
នៅពេលដែលយើងចេញមកខាងក្រៅ ពួកគាត់នឹងប្រមូល ពួកគាត់នឹងប្រគល់
ពួកគាត់នឹងប្រគល់ចំណីនោះឲ្យមកយើងវិញ។ អញ្ចឹងនៅពេលដែលយើងចូលមើលកុន
ជាទូទៅយើង យើងយកបានតែពោតលីងនិងទឹកតែប៉ុណ្ណោះ។
អញ្ចឹងពួកគាត់ទាំងពីរបានទិញពោតលីងដើម្បីញ៉ាំលេងនៅពេលដែលមើលកុន កុំឲ្យ កុំឲ្យអផ្សុក
ឬក៏កុំឲ្យធុញ។ ពីព្រោះពេលខ្លះនៅពេលដែលយើងគ្រាន់តែមើលកុន ប៉ុន្តែអត់មានអីញ៉ាំលេង
ពេលខ្លះមានអារម្មណ៍ថាអផ្សុកមាត់ដោយសារ ដោយសារតែអត់មានអ្វីទំពានៅក្នុងមាត់
អញ្ចឹងពួកគាត់ទាំងពីរបានទិញ បានទិញពោតមួយប្រអប់ធំ
ជាទូទៅពោតលីងដែលលក់នៅតាមរោងកុនតម្លៃ តម្លៃ ពោតខ្លះតម្លៃ ២ ដុល្លារ ក្នុងមួយប្រអប់
ពោតខ្លះតម្លៃ ៣ ដុល្លារ ទៅតាម ទៅតាមប្រអប់ធំ ឬក៏ប្រអប់តូច ទៅតាមប្រអប់ធំ ឬក៏ប្រអប់តូច
ប៉ុន្តែតម្លៃដែលថ្លៃបំផុតត្រឹមតែ ៣ ដុល្លារ តែប៉ុណ្ណោះ បន្ទាប់មកទៀត យើងឃើញ
ក្រោយពេលដែលពួកគាត់បាន
ក្រោយពេលដែលពួកគាត់បានប្រាប់អ្នកលក់ឲ្យយកពោតលីងមួយប្រអប់
អ្នកលក់ក៏បានដាក់ពោតលីងនោះចូលទៅក្នុងប្រអប់ធំមួយ និងបានហុចប្រគល់ឲ្យពួកគាត់ទាំងពីរ។

បន្ទាប់មកទៀតរូបភាពទី រូបភាពទី ៦ ក្រោយពេលដែលគាត់ទិញពោតលីងហើយ
គាត់ក៏បានហៅកូកា ឬក៏គាត់ក៏បានទិញកូកាពីរដបទៀត
ដោយសារតែនៅពេលដែលគាត់ញ៉ាំពោតលីង ប្រហែលជា

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅពេលដែលគាត់ញ៉ាំពោតលីងគាត់នឹងស្រេកទឹក អញ្ចឹងនៅពេលដែលគាត់កំពុងតែមើលកុន
អញ្ចឹងពិបាកនឹងដើរចេញមកខាងក្រៅទិញទឹក និងត្រលប់ចូលទៅខាងក្នុងវិញ
ដូច្នេះមុនពេលដែលគាត់ចូលគាត់ត្រូវទិញពោតលីង និងទឹកទុកជាមុនសិន ទុកជាមុនសិន
ងាយស្រួលនៅពេលដែលគាត់មើលកុន មិនចាំបាច់ដើរចេញមកខាងក្រៅ
អញ្ចឹងអ្នកលក់បានហុចកូកាឲ្យគាត់ចំនួនពីរដប
និងដាក់ទុយោសម្រាប់បឺតនៅក្នុងដបនីមួយៗផងដែរ។

បន្ទាប់មកទៀតយើងឃើញរូបភាពទី ៧ រូបភាពទី ៧ ដែលយើងឃើញពួកម៉ាករបស់គាត់
ដៃម្ខាងកាន់ពោតលីង ដៃម្ខាងទៀតកាន់កូកានៅក្នុង កាន់កូកាមួយដបនៅក្នុងដៃរបស់គាត់
និងពួកម៉ាករបស់គាត់ និងស្ត្រីម្នាក់នោះយើងឃើញកាន់កូកាមួយដបនៅក្នុងដៃ
និងមានកាន់សំបុត្រនៅក្នុងដៃរបស់គាត់
អញ្ចឹងសំបុត្រនោះយើងត្រូវប្រគល់ឲ្យទៅអ្នកដែលគាត់ជាអ្នកត្រួតពិនិត្យសំបុត្រ
ដែលឈរនៅខាងមុខទ្វារចូលទៅមើលកុននោះ យើងឃើញគាត់ស្លៀកពាក់ជាឯកសណ្ឋាន
ជាឯកសណ្ឋាន ជាអ្នកឆែកសំបុត្រ នៅពេលដែល[ភ្ញៀវ] នៅពេលដែលភ្ញៀវដើរចូលទៅខាង[ក្នុង]
នៅពេលដែលមនុស្សចូលទៅមើលកុននៅខាងក្នុង
ឬក៏នៅពេលដែលភ្ញៀវចូលទៅមើលកុននៅខាងក្នុង។ គាត់ត្រូវឆែកសំបុត្រឲ្យច្បាស់សិន
មុនពេលដែលអនុញ្ញាតឲ្យពួកគាត់ចូលទៅខាងក្នុង
ពីព្រោះអ្នកខ្លះគាត់បន្លំចូលដោយការមិនបានទិញសំបុត្រ ដូច្នេះកៅអីមានកំណត់
ប្រសិនបើគាត់បន្លំចូលដោយគ្មានសំបុត្រ ពួកយើងមិនអនុញ្ញាតឲ្យគាត់ចូលទៅទេ
អញ្ចឹងមុនពេលដែលចូលពួកគាត់ត្រូវទិញសំបុត្រ និងឲ្យច្បាស់ថាគាត់ត្រូវចូលខ្លោងទ្វារមួយណា
ឬក៏ច្រកចូលមួយណា និងគាត់ ពួកគាត់មើលកុនមួយណា
អញ្ចឹងគាត់បានប្រគល់សំបុត្រឲ្យទៅអ្នកដែលឆែកសំបុត្រនៅខាងមុខទ្វារកុននោះ
បន្ទាប់មកអ្នកមើល អ្នកឆែកសំបុត្រក៏បានពិនិត្យមើលសំបុត្ររបស់ពួកគាត់
មុនពេលដែលអនុញ្ញាតឲ្យពួកគាត់ទាំងពីរចូលទៅខាងក្នុង។

បន្ទាប់មកទៀតរូបភាពទី រូបភាពទី ៨ រូបភាពទី ៨ ក្រោយពេលឆែកសំបុត្ររួចរាល់ហើយ
ពួកគាត់ក៏ដើរចូលមកខាងក្នុងដើម្បីរកកន្លែងអង្គុយរបស់ពួកគាត់
អញ្ចឹងជាទូទៅកៅអីដែលនៅខាងក្នុងគឺយើងមានដាក់លេខសម្គាល់
អញ្ចឹងយើងអាចចាំលេខសម្គាល់ដែលមាននៅក្នុង ដែលមាននៅក្នុងសំបុត្រ
ដែលយើងបានទិញនៅខាងក្រៅ អញ្ចឹងយើងអាចរកលេខនោះដើម្បីរកកន្លែងអង្គុយ
ពេលខ្លះប្រសិនបើអង្គុយខុស អ្នកដែលឆែកសំបុត្រគាត់នឹងមក គាត់នឹងមកប្រាប់យើង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីឲ្យយើងប្តូរកន្លែង ប្រសិនបើរោងកុនមានមនុស្សច្រើន អ្នក អ្នក
អ្នកឆែកសំបុត្រនឹងប្រាប់យើងឲ្យដូរកន្លែង ប៉ុន្តែប្រសិនបើរោងកុនមិនសូវមានមនុស្សច្រើនទេ
យើងអាចអង្គុយកន្លែងណាក៏បានដែរ យើងអាចអង្គុយនៅខាងមុខ ឬក៏ខាងក្រោយគេបង្អស់
ឬក៏ចំហៀង ខាង[ឆ្វេង] ខាងឆ្វេង ឬក៏ចំហៀងខាងស្តាំ
ប៉ុន្តែជាទូទៅមនុស្សគាត់ចូលចិត្តអង្គុយនៅខាងក្រោយ ពីព្រោះងាយស្រួលមើល
ដោយសារតែរូបភាពគឺអត់ធំៗ និង និងច្បាស់ ងាយស្រួលមើល អញ្ចឹងយើងឃើញពួកគាត់ទាំងពីរ
យើងឃើញពួកគាត់ទាំងពីរកំពុងរកកៅអីអង្គុយ ដែលយើងឃើញមានមនុស្សជា
មានមនុស្សជាច្រើនអង្គុយនៅក្នុងរោងកុននោះដើម្បីចាំមើលកុននោះ
អញ្ចឹងយើងឃើញពួកគាត់ទាំងអស់គ្នា អ្នកខ្លះអង្គុយបាននូវកៅអីមុខ អ្នកខ្លះអង្គុយ
អ្នកខ្លះទិញសំបុត្រកៅអីក្រោយអត់បាន ដូច្នេះពួកគាត់ក៏អង្គុយនៅកៅអីមុខ
អ្នកខ្លះទៀតបានកក់សំបុត្រ ឬក៏ទិញសំបុត្រនៅកៅអីក្រោយបាន
ដូច្នេះអ្នកខ្លះគឺគាត់អង្គុយនៅកៅអីក្រោយ
អញ្ចឹងយើងឃើញមានមនុស្សជាច្រើននៅក្នុងរោងកុននោះ។

បន្ទាប់មកទៀតរូបភាពទី ៩ រូបភាពទី ៩ ក្រោយពេលដែលគាត់រកកន្លែងអង្គុយហើយ
យើងឃើញគាត់ទិញសំបុត្រអង្គុយនៅកៅអីក្រោយ អង្គុយនៅកៅអីក្រោយ
អញ្ចឹងកៅអីនោះគឺជាប់ៗគ្នា កៅអីនោះគឺជាប់ៗគ្នា
អញ្ចឹងក្រោយពេលដែលគាត់រកកន្លែងអង្គុយបានហើយពួកគាត់ក៏អង្គុយ
បន្ទាប់មកពួកគាត់ក៏ដាក់ដបកូកាកូឡាទៅក្នុងប្រហោងកៅអីនោះ
អញ្ចឹងកៅអីនោះយើងមានប្រហោងតូចមួយសម្រាប់ដាក់ដបកូកាកូឡា
ដូច្នេះយើងមិនចាំបាច់កាន់នៅក្នុងដៃរបស់យើងទេ
នៅពេលដែលយើងស្រេកទឹកយើងអាចយកកូកាកូឡានោះមកញ៉ាំ
នៅពេលដែលយើងញ៉ាំឆ្អែតហើយ យើងអាចដាក់ត្រលប់ចូលទៅកន្លែងដើមវិញ។
អញ្ចឹងយើងឃើញពួកម៉ាករបស់គាត់កាន់ កាន់ពោតលីងនៅក្នុងប្រអប់យ៉ាងជាប់
និងពួកម៉ាករបស់គាត់ និង អញ្ចឹងពួកម៉ាករបស់គាត់កាន់ កាន់ពោតលីងនៅក្នុងដៃរបស់គាត់
និងស្ត្រីម្នាក់ទៀតយើងឃើញគាត់ដាក់កូកាកូឡាទៅក្នុងប្រហោងកៅអីនោះ
ទៅក្នុងប្រហោងកៅអីនោះ។ អញ្ចឹងពោតលីងមួយប្រអប់ពួកគាត់ញ៉ាំជាមួយគ្នា
អញ្ចឹងពួកគាត់ញ៉ាំជាមួយគ្នា។

បន្ទាប់មកទៀតរូបភាពទី ១០ រូបភាពទី ១០ គឺយើងឃើញមុនពេលដែលមានការបញ្ចាំងរឿង
ឬក៏មុនពេលដែលកុនចាប់ផ្តើម មានការផ្សាយពាណិជ្ជកម្ម ឬក៏ជារឿងខ្លីៗ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏ពាណិជ្ជកម្មរឿងខ្លីៗជាមុនសិនមុនពេលដែលកុនចាប់ផ្ដើម
អញ្ចឹងប្រសិនបើកុនចាប់ផ្ដើមនៅម៉ោងបួនឧទាហរណ៍ កុនចាប់ផ្ដើមនៅម៉ោងបួន
នៅពេលដែលយើងមកដល់មុនម៉ោង យើង នៅពេលដែលយើងមកដល់មុនម៉ោង
យើងមើលពាណិជ្ជកម្មដែលផ្សាយ ដែលផ្សាយមុនពេល មុនពេលបញ្ចាំងរឿងសិន
ដែលផ្សាយមុនពេលបញ្ចាំងរឿងសិន អញ្ចឹងអ្នកខ្លះគាត់ចូលចិត្តមកមុនម៉ោង
ដោយសារតែពេលខ្លះងាយស្រួលក្នុងការរកកៅអី ពីព្រោះនៅពេលដែលយើងបញ្ចាំងរឿង
ពួកគាត់នឹងបិទភ្លើង ពួកគាត់នឹងបិទភ្លើង ដូច្នេះធ្វើឲ្យយើងពិបាករកកន្លែងអង្គុយ
និងពិបាកដើរផងដែរ យើងអាច នៅពេលដែលដើរអាច អាចបុកនឹងជើងរបស់កៅអី
ឬក៏ពេលខ្លះអាចដើរធ្លាក់កាំជណ្ដើរ អញ្ចឹងអ្នកខ្លះគាត់ចូលចិត្តមកមុន មុនបញ្ចាំងរឿង ប្រាំនាទី
ឬក៏មុនបញ្ចាំងរឿងប្រាំនាទី ឬក៏ប្រាំ ឬក៏ដប់នាទីមុន ដោយសារតែងាយស្រួលក្នុងការរកកន្លែងអង្គុយ
ងាយស្រួលក្នុងការរកកន្លែងអង្គុយ និងពួកគាត់អាចមើលការផ្សាយពាណិជ្ជកម្មនៅ
នៅក្នុងរោងកុននោះផងដែរ។ ដែលយើងឃើញការផ្សាយពាណិជ្ជកម្មនោះ
គឺជាការផ្សាយពាណិជ្ជកម្មអំពីឡាន អំពីឡាន
ប្រហែលជាឡាននោះគឺជាឡានសេរីថ្មីដែលទើបនឹងចេញ ដូច្នេះមានការផ្សាយពាណិជ្ជកម្មឲ្យមនុស្ស
មានការផ្សាយពាណិជ្ជកម្មឲ្យពួកគាត់មើល ពីព្រោះប្រសិនបើគាត់ចាប់អារម្មណ៍ក្នុងការទិញឡាន
ពួកគាត់អាច ពួកគាត់អាច ពួកគាត់អាចទិញឡានដែលជាសេរីថ្មីនៅក្នុងការផ្សាយពាណិជ្ជកម្មនោះ។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ ក្រោយពេលដែលការផ្សាយពាណិជ្ជកម្មចប់
និងដល់ពេលដែលចាប់ផ្ដើមបញ្ចាំងកុនផង អញ្ចឹងដូច្នេះ ដូច្នេះ ដូច្នេះពួកគាត់ក៏បិទពាណិជ្ជកម្ម
និងចាប់ផ្ដើមបញ្ចាំងកុនឲ្យមនុស្សទាំងអស់នៅក្នុងរោងកុនគាត់បានមើល ឬក៏ទស្សនា
អញ្ចឹងមុនពេលដែល មុនពេលដែលមានជាសាច់រឿង យើងត្រូវ មុនពេលមានជាសាច់រឿង
មុនពេលបញ្ចាំងជាសាច់រឿងគាត់ត្រូវដាក់ចំណងជើង គាត់ត្រូវបញ្ចាំង គាត់ត្រូវ គាត់ត្រូវបង្ហាញអំពី
គាត់ត្រូវបង្ហាញអំពីចំណងជើងរបស់រឿងជាមុនសិន ចំណងជើងរបស់រឿងជាមុនសិន
អញ្ចឹងនៅពេលដែលចាប់ផ្ដើមបញ្ចាំងរឿង មនុស្សទាំងអស់នៅ នៅក្នុងរោងកុននោះ គាត់ចាប់ផ្ដើម
គាត់ចាប់ផ្ដើមស្ងប់ស្ងាត់ និងយកចិត្តទុកដាក់ក្នុងការមើលកុន
យកចិត្តទុកដាក់មើលកុននៅក្នុងរោងកុននោះ អញ្ចឹងនៅពេលដែល មុន មុនពេលបញ្ចាំងរឿងគឺ
រោងកុនគឺភ្លឺ ដោយសារតែពួកគាត់បើកភ្លើង ប៉ុន្តែនៅពេលដែលបញ្ចាំងរឿង ពួកគាត់នឹងបិទភ្លើង
ពួកគាត់នឹងបិទភ្លើង អញ្ចឹងរោងកុនចាប់ផ្ដើមងងឹត និងមានពន្លឺខ្លះចេញពីកុននោះ។

បន្ទាប់មករូបភាពទី ១២ រូបភាពទី ១២ កុនក៏បានចាប់ផ្ដើម កុនក៏បានចាប់ផ្ដើម
យើងឃើញកុននេះប្រហែលជាកុនស្នេហា ប្រហែលជាកុនស្នេហាដែលយើងឃើញមានបុរសម្នាក់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងស្ត្រីម្នាក់ គាត់កំពុងតែជជែកគ្នាលេង និងសាសងគ្នានៅក្នុងរឿងកុន នៅក្នុងរឿងកុននេះ
អញ្ចឹងប្រហែលជា ជារឿងកុនស្នេហា អញ្ចឹងយើងឃើញពួកគាត់ដែលអង្គុយនៅក្នុងរោងកុននោះ
ពួកគាត់មើលយ៉ាង មើលយ៉ាងរំភើប និងសប្បាយរីករាយ
ដោយសារតែរឿងនោះគឺជារឿងបែបស្នេហានិងផ្អែមល្ហែម ស្នេហានិងផ្អែមល្ហែម។

បន្ទាប់មកទៀតរូបភាពទី ១៣ រូបភាពទី ១៣ មួយម៉ោងកន្លងផុតទៅរឿងនោះក៏បានចប់
រឿងកុននោះ រឿងកុនដែលបានបញ្ចាំងនោះក៏បានចប់ អញ្ចឹងមនុស្សដែល
មនុស្សដែលចូលទៅមើលកុននោះក៏ចាប់ផ្តើម ក៏ចាប់ផ្តើមរៀបចំចេញមកខាងក្រៅត្រលប់ទៅផ្ទះវិញ
ដើម្បីត្រលប់ទៅផ្ទះ ឬក៏ត្រលប់ទៅដើរលេងបន្តនៅកន្លែងផ្សេងទៀត
ដោយសារតែរឿងនោះបានចប់ហើយ។

បន្ទាប់មកទៀតរូបភាពទី ១៤ រូបភាពទី ១៤ អ្នកខ្លះបានដើរចេញទៅខាងក្រៅ
អ្នកខ្លះទៀតកំពុងតែរៀបចំចេញទៅខាងក្រៅ កំពុងតែរៀបចំដើរចេញពីរោងកុន ពីព្រោះអ្នកខ្លះគាត់
គាត់កំពុង អ្នកខ្លះគាត់ជជែកគ្នាបន្តិចមុនពេលដែលចេញពីរោងកុន
ដោយសារតែពួកគាត់ចង់ទៅបន្តនៅកន្លែងផ្សេងទៀត អញ្ចឹងយើងឃើញ
យើងឃើញពួកគាត់ទាំងពីរក៏បានដើរចេញពីកៅអី និងដើរចេញទៅខាងក្រៅ
ដើម្បីត្រលប់ទៅផ្ទះវិញ។ ពួកគាត់ដើរបណ្តើរជជែកគ្នាបណ្តើរ
អញ្ចឹងពួកគាត់ដើរបណ្តើរជជែកគ្នាបណ្តើរ។

បន្ទាប់មករូបភាពទី ១៥ រូបភាពទី ១៥ ពួកគាត់ក៏ដើរចេញមកពីផ្សារទំនើប
អញ្ចឹងដំបូងគាត់ដើរចេញពីកន្លែងមើលកុនសិន
បន្ទាប់មកគាត់ក៏បានចុះមកខាងក្រោមចេញពីផ្សារទំនើប ដើម្បីចេញ
ដើម្បីដើរចេញមកយកម៉ូតូត្រលប់ទៅផ្ទះវិញ ដោយសារតែផ្ទះរបស់ពួកគាត់នៅផ្លូវខុសគ្នា
ដូច្នេះយើងឃើញពួកគាត់ជិះម៉ូតូផ្សេងៗគ្នា និងទៅផ្លូវខុសគ្នា។ អញ្ចឹងយើងឃើញ
យើងឃើញពួកម៉ាករបស់គាត់មុនពេលដែលត្រលប់ទៅផ្ទះវិញ គាត់ក៏បានដាក់ចន្ទល់ម៉ូតូ
ដាក់ចន្ទល់ម៉ូតូសិន បន្ទាប់មកគាត់ក៏បានពាក់មួកសុវត្ថិភាព និងលើកដៃលាទៅពួកម៉ាករបស់គាត់
អញ្ចឹងពួកម៉ាករបស់គាត់បានបណ្តើរម៉ូតូ
និងងាកខាងក្រោយដើម្បីនិយាយលាទៅកាន់ពួកម៉ាករបស់គាត់វិញ
ដើម្បីនិយាយលាទៅកាន់ពួកម៉ាករបស់គាត់វិញ អញ្ចឹងពួកគាត់ទាំងពីរត្រលប់ទៅផ្ទះរៀងៗខ្លួន
ដោយជិះផ្លូវខុសគ្នា ដោយជិះម៉ូតូត្រលប់ទៅផ្ទះវិញផ្លូវខុសគ្នា។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី [៥] រូបភាពទី ១៦ ក្រោយពេលដែលគាត់បានលា
ក្រោយពេលដែលគាត់លាគ្នាហើយ គាត់ក៏បានជិះម៉ូតូត្រលប់មកផ្ទះរបស់គាត់វិញ
គាត់នៅតែពាក់មួកសុវត្ថិភាពរបស់គាត់ជានិច្ចរាល់ពេលដែលគាត់ជិះម៉ូតូ រាល់ពេលដែលជិះម៉ូតូ
និងគាត់ជិះម៉ូតូត្រលប់មកផ្ទះវិញយឺតៗ ដោយសារតែ ដោយសារតែគាត់មិនប្រញាប់
គាត់មិនប្រញាប់ គាត់មិនប្រញាប់ត្រលប់មកផ្ទះវិញទេ ដោយសារដំបូង
ដោយសារដំបូងគាត់ជិះម៉ូតូលឿន ដោយសារគាត់ខ្លាចពួកម៉ាករបស់គាត់មកដល់មុន និងចាំគាត់យូរ
ដូច្នេះគាត់ត្រូវជិះម៉ូតូលឿនដើម្បីប្រញាប់ជួបពួកម៉ាករបស់គាត់
អញ្ចឹងនៅពេលដែលគាត់ត្រលប់មកផ្ទះវិញ គាត់ជិះម៉ូតូធម្មតា គឺមិនលឿនទេ គាត់ជិះម៉ូតូល្មម
គាត់ជិះម៉ូតូដោយល្បឿនល្មម ដោយគាត់មិនសូវប្រញាប់មកផ្ទះ
ដោយសារតែគាត់មិនប្រញាប់មកផ្ទះ ដោយសារតែ ដោយសារតែអត់មានអ្នកណានៅផ្ទះ
ដូច្នេះគាត់មិនចាំបាច់ប្រញាប់មក មកផ្ទះពេកទេ គាត់អាចជិះម៉ូតូសន្សឹមៗ ឬក៏ជិះម៉ូតូយឺតៗ
ជិះម៉ូតូយឺតៗដើម្បីកុំឲ្យមានគ្រោះថ្នាក់ ពេលខ្លះការជិះម៉ូតូលឿនអាចមានគ្រោះថ្នាក់
ដោយសារតែពេលខ្លះប្រសិនបើយើងចាប់ហ្វ្រាំងអត់ទាន់ អាចធ្វើឲ្យយើងបុកគេ
ឬក៏អាចធ្វើឲ្យយើងដួលបាន និងអាចធ្វើឲ្យយើងដួល និងមានរបួសផងដែរ អញ្ចឹងការជិះម៉ូតូយឺតៗ
គឺល្អ និងអាច និងអាចឲ្យយើងមានសុវត្ថិភាពផងដែរ។

បន្ទាប់មកទៀតរូបភាពទី ១៧ នៅពេលដែលគាត់ជិះម៉ូតូត្រលប់មកដល់ផ្ទះហើយ
គាត់ក៏បានដើរចូលទៅក្នុងផ្ទះ បន្ទាប់មកគាត់ក៏បានអង្គុយនៅកៅអីរបស់គាត់ដោយ
និងប្រើកុំព្យូទ័ររបស់គាត់ម្តងទៀត អញ្ចឹងគាត់ នៅពេលដែលគាត់មកដល់ផ្ទះ
មុនពេលដែលគាត់ចូលគេង គាត់បានឆាតនិយាយជាមួយនឹងពួកម៉ាករបស់គាត់ និងបានប្រាប់របស់
និងបានប្រាប់ពួកម៉ាករបស់គាត់ និងប្រាប់ពួកម៉ាករបស់គាត់ថា ថាគាត់នឹងចូលគេងឆាប់ៗ
អញ្ចឹងមុនពេលគេងគាត់ត្រូវនិយាយរាត្រីសួស្តីទៅកាន់ពួកម៉ាករបស់គាត់សិន
ទៅកាន់ពួកម៉ាករបស់គាត់សិន អញ្ចឹងគាត់អង្គុយ គាត់អង្គុយនៅលើកៅអី
ឆាតជាមួយនឹងពួកម៉ាករបស់គាត់ និងនិយាយរាត្រីសួស្តី បន្ទាប់មកគាត់ក៏បាន
គាត់ក៏បានដើរចូលទៅក្នុងបន្ទប់គេង ដោយសារតែគាត់ ដោយសារតែគាត់អស់កម្លាំង
ដោយសារតែគាត់អស់កម្លាំង ដោយសារតែគាត់អស់កម្លាំង ពីព្រោះគាត់ជិះម៉ូតូ
ពីព្រោះគាត់ជិះម៉ូតូទៅមើលកុន គាត់ជិះម៉ូតូទៅមើលកុននៅថ្ងៃនេះ ជាមួយនឹងពួកម៉ាករបស់គាត់
និងកុននោះល្អមើល
និងពួកគាត់ទាំងពីរមើលកុនបណ្តើរជជែកគ្នាបណ្តើរយ៉ាងសប្បាយរីករាយនៅថ្ងៃឈប់សម្រាកនោះ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.